ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តព្រៃវែង

លេខ ០១០ សជណ/១១

# សេចក្តីជូនដំណឹង

## ស្តីពី

## ពន្ធលើឈ្នួលផ្ទះ និង ដី

- បានឃើញប្រកាសលេខ ០២១ប្រក.សហវ.ពដ ចុះថ្ងៃទី ០២ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីការគ្រប់គ្រងពន្ធលើឈ្នួលផ្ទះនិងដី

អភិបាលនៃគណៈអភិបាលខេត្តសូមជូនដំណឹងថា៖

១- ត្រូវប្រកាសបង់ពន្ធឈ្នួលផ្ទះនិងដី ក្នុងរយៈពេល ១៥ ថ្ងៃគិតពីថ្ងៃចុះកិច្ចសន្យាជួល ឬចាប់ពីថ្ងៃមានការប្រែប្រួលអំពីកិច្ចសន្យា ជូនទៅស្នាក់ការពន្ធដារស្រុក ដោយភ្ជាប់ជាមួយនូវច្បាប់ថតចម្លងនៃកិច្ចសន្យាជួលចំនួន ១ ច្បាប់។

២- ពេលឈប់ជួលក្នុងរវាង ១៥ ថ្ងៃ ត្រូវប្រកាសជាលាយលក្ខណ៍អក្សរ ជូនទៅស្នាក់ការពន្ធដារស្រុក។

៣- កម្មសិទ្ធិករត្រូវបង់ពន្ធឈ្នួលផ្ទះនិងដីចាប់ពីថ្ងៃទី ២០ ដល់មុនដំណាច់ខែចំនួន ២ ថ្ងៃនៃខែប្រមូលពន្ធ។

៤- ក្នុងករណីកម្មសិទ្ធិករមិនព្រមបង់ពន្ធ នោះអ្នកជួលមានភារកិច្ចទទួលខុសត្រូវដកប្រាក់ឈ្នួលបង់ពន្ធជំនួស។

៥- អ្នកជួលផ្ទះនិងដី ត្រូវផ្តល់ពត៌មាននានាដែលទាក់ទងនឹងការជួល ដល់ភ្នាក់ងារមានសមត្ថកិច្ចត្រួតពិនិត្យ។

៦- កម្មសិទ្ធិករដែលមានផ្ទះនិងដីជួល មិនបានប្រកាសបង់ពន្ធឈ្នួលផ្ទះនិងដី នោះនៅពេលដែលក្រុមសមត្ថកិច្ចត្រួតពិនិត្យឃើញ ត្រូវរងនូវការផាកពិន័យតាមច្បាប់ជាធរមាន។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ អភិបាលនៃគណៈអភិបាលខេត្តមានជំនឿថា គ្រប់កម្មសិទ្ធិករទាំងអស់ដែលមានផ្ទះនិងដីជួល នឹងយកចិត្តទុកដាក់អញ្ជើញទៅប្រកាសបង់ពន្ធ បានទាន់ពេលវេលាកំណត់ជាមិនខានឡើយ។

ព្រៃវែង,ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១១

**អភិបាលនៃគណៈអភិបាលខេត្ត**

**អ៊ុង_សាមី**

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមប្រឹក្សាខេត្តព្រៃវែង
  "គោរពជូនជ្រាប"
- សាលាស្រុក-ក្រុង
- សាខាពន្ធដារខេត្ត
- និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ